ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល
សភាថ្នាក់រដ្ឋប្បវេណី
សំណុំរឿងរដ្ឋប្បវេណី
លេខ : ២៦៧
ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩៩៧

---

សាលដីកា
លេខ : ១៤២
ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ ១៩៩៨

តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

បានបើកសវនាការជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី ១៧ ខែសីហា ឆ្នាំ ១៩៩៨ ដោយមានសមាសភាពដូចតទៅ :

១-ឯកឧត្តម ឌិត មុន្តី ជាប្រធាន
២-លោក ម៉ែប៊ុន ស៊ុន ជាចៅក្រម
៣- លោក ទៀល មួន ជាចៅក្រម
៤-លោក ជីវ កេង ជាចៅក្រមរបាយការណ៍
៥-លោក ស៊ុន ឌីម ជាចៅក្រម
ក្រឡាបញ្ជី លោកស្រី ទី រ៉ាវី

តំណាងមហាអយ្យការ លោក ម៉ែចំ សារឿន ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាលេខ ២៦២ ចុះថ្ងៃទី ២០.៥.៩៧ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៣៣៣ ចុះថ្ងៃទី ១១.៧.៩៦ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ តិប ទង់ ភេទប្រុស អាយុ ៥១ឆ្នាំ សញ្ជាតិខ្មែរ របររកស៊ី ចែងព្រួល ទីលំនៅសព្វថ្ងៃ ភូមិល្អាកែត ស្រុកស្វាយចេក ខេត្តបាត់ដំបង ។
ឪពុកឈ្មោះ ខូល ឈួន "ស" ម្តាយឈ្មោះ ស៊ុន តុង "ស" ។

និង ចុងបណ្តឹងសាទុក្ខឈ្មោះ ឈូ ហាក់តាង ភេទស្រី អាយុ ៣៣ឆ្នាំ សញ្ជាតិខ្មែរ របររកស៊ី លក់ដូរ ទីលំនៅសព្វថ្ងៃ ភូមិល្អាកែត ស្រុកស្វាយចេក ខេត្តបាត់ដំបង ។
ឪពុកឈ្មោះ ឈូ សៀក "រ" ម្តាយឈ្មោះ គួយ ម៉ែ "រ" ។

កម្មវត្ថុបណ្តឹង : ប្តឹងសុំសិទ្ធិគ្រប់គ្រងដី និង សុំអោយចុងចម្លើយឈ្មោះតិប ទង់ រុះរើផ្ទះចេញ ។

តាមបណ្តឹងសាទុក្ខលេខ ១៨៧ ចុះថ្ងៃទី ០៣.៦.៩៧ របស់ឈ្មោះ តិប ទង់ ប្តឹងមិនសុខចិត្តពីសាលដីកាលេខ ២៦២ ចុះថ្ងៃទី ២០.៥.៩៧ របស់សាលាឧទ្ធរណ៍ លើចំនុចនៃ សេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២៦៧ ចុះថ្ងៃទី ២២.៩.៩៧ របស់ តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ១៥.៣.៩៥ របស់ដើមចោទឈ្មោះ ឈូ ហាក់តាង ប្តឹងសុំសិទ្ធិគ្រប់គ្រងដី និង សុំអោយចុងចម្លើយ ឈ្មោះ តិប ទង់ រុះរើផ្ទះចេញ ដោយរាង

ហេតុថា នៅឆ្នាំ ១៩៨៣ ឈ្មោះ កាក់ ប៊ុយ បានមកសុំដីខ្លួនសង់ផ្ទះស្នាក់នៅ ទំហំ ៤ម គុណ ៥ម រហូតដល់ឆ្នាំ ១៩៨៥ ទើបចេញវិញ ។ បន្ទាប់មកឈ្មោះ តិប ទង់ បានសុំដីរបស់ខ្លួនស្នាក់នៅជាបណ្ដោះអាសន្ន ។ ក្នុងការរស់នៅឈ្មោះ តិប ទង់ មិនបានដាំផ្ទះអ្វីទេ និងពុំបានចាត់ចែងលើដីធ្លី និង ផលដំណាំ របស់ខ្លួនឡើយ ដី និង ដំណាំចាស់ទាំងអស់ ស្ថិតនៅលើក្រុមគ្រួសារ របស់ខ្លួនចាត់ចែង និង អាស្រ័យផល ។

បានឃើញរាយការណ៍ក្រមលេខ ២៣០ ចុះថ្ងៃទី ២៤.១១.៨៥ របស់តុលាការខេត្តបាត់ដំបង ដែលមានខ្លឹមសារ នៃសេចក្ដីសំរេចដូចតទៅ

១-ក.ទទួលពាក្យបណ្ដឹងចុះថ្ងៃទី ១៥.៣.៨៥ របស់ឈ្មោះនាង ញូ ហាក់ឆាង ជាដើមចោទ ប្ដឹងសុំសិទ្ធិគ្រប់គ្រងដីចំការជាកម្មសិទ្ធិ និង សុំអោយចុងចម្លើយឈ្មោះ ទិប ទង់ រុះរើផ្ទះចេញ ពីដីចំការ ទុកជាត្រឹមត្រូវតាមទំនងច្បាប់ តែមិនសេរីមោឃ ដោយខុសនឹងគតិច្បាប់ ។

ខ.ទទួលយកសំណើតប ប្ដឹងសុំនាពេលសវនាការរបស់ចុងចម្លើយឈ្មោះ តិប ទង់ សុំសិទ្ធិគ្រប់គ្រងដីចំការ ទុកជាត្រឹមត្រូវតាមទំនង និង គតិច្បាប់ ។

២-ប្រគល់ដីចំការ អោយចុងចម្លើយ ឈ្មោះ តិប ទង់ អាស្រ័យផលប្រើប្រាស់ និង អាស្រ័យនៅ ចាប់ពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ ដោយផ្អែកតាមប្លង់បង្ហាញទីតាំងដីចំការ មាត្រដ្ឋាន ១ : ៥០០ ចុះថ្ងៃទី ១៧.៦.៨៥ របស់ការិយាល័យសុរិយោដីខេត្តបាត់ដំបង ដែលមានរាងជាពហុកោណប៉ោង BCDEE' មានរង្វាស់ជ្រុងនីមួយៗ គឺ :
|BC|= ១០,៥០ម, |CD|=១៧,៥០ម, |DE|=២,៧០ម |EE'|=៨,៧០ម និង|E'B|=៧,១០ម ស្ថិតនៅភូមិស្លាកែត ឃុំស្លាកែត ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

៣-ប្រគល់ដំណាំដូងចំនួន ០៣ ដើម នៅលើដីចំការអោយឈ្មោះតិបទង់ គ្រប់គ្រងអាស្រ័យផល តែអោយឈ្មោះនេះចេញថ្លៃដំណាំដូងចំនួន ០៣ដើមនេះទៅដើមចោទឈ្មោះ នាង ញូ ហាក់ឆាង ជាប្រាក់រៀលចំនួន ១០០.០០០៛ គុណ ៣ : ៣០០.០០០៛ "បីសែនរៀលគត់" ចាប់ពីថ្ងៃសាលក្រមនេះចូលជាស្ថាពរ ។

តាមអនុក្រឹត្យលេខ ២៥ អនក្រ ចុះថ្ងៃទី ២២.៤.៨៩ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃរដ្ឋកម្ពុជា

តាមមាត្រា ៥ និង មាត្រា ២៨ នៃច្បាប់ភូមិបាល ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ១០០ក្រ ចុះថ្ងៃទី ១៣.១០.៩២ របស់ក្រុមប្រឹក្សារដ្ឋ នៃ រដ្ឋកម្ពុជា ។

៤-រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន ៧.០០០៛ របស់ដើមចោទ ដោយ :

-បង់ពន្ធចុះបញ្ជីក្ដី និងពន្ធតែម ចំនួន ១.៨០០៛

-រង្វាន់ក្រឡាបញ្ជីការពិនប្រាក់ ចំនួន ២០០៛

-រង្វាន់អ្នកប្រគល់ដីការកោះ ចំនួន២.០០០៛

-ចំណាយក្នុងកិច្ចស៊ើបសួរ ចំនួន ៣.០០០៛

តាមច្បាប់ស្ដីពីប្រាក់ប្រដាប់ក្ដី ដែលប្រកាសឲ្យប្រើ តាមក្រឹត្យលេខ ០៧ក្រ ចុះថ្ងៃទី ០៨.០២.៨៣ របស់ក្រុមប្រឹក្សារដ្ឋ នៃ រដ្ឋកម្ពុជា ។

សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខគូភាគី ។

បើកផ្លូវឧទ្ធរណ៍ កំណត់ ២ខែ គិតពីថ្ងៃប្រកាសសាលក្រម ។

បានឃើញបណ្ដឹងឧទ្ធរណ៍របស់ឈ្មោះ គិប ទង់ ចុះថ្ងៃ ១៣.១២.៨៥ ប្ដឹងមិនសុខចិត្ត នឹង សាលក្រមរដ្ឋប្បវេណីលេខ ២៧០ ចុះថ្ងៃទី ២៤.១១.៨៥ របស់តុលាការខេត្តបាត់ដំបង ត្រង់ចំនុចទី ៣ នៃសេចក្ដីសំរេច ។

បានឃើញបណ្ដឹងឧទ្ធរណ៍ របស់ឈ្មោះ ឈួ ហាក់គាង ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ ១៩៨៦ ប្ដឹងមិនសុខចិត្ត លើសេចក្ដីសំរេច នៃសាលក្រមខាងលើ ។

បានឃើញសាលដីការបស់សាលាឧទ្ធរណ៍លេខ ២៦២ ចុះថ្ងៃទី ២០.៥.៨៧ ដែលមានខ្លឹមសារ នៃសេចក្ដីសំរេចដូចតទៅ ។

១-ទទួលបណ្ដឹងឧទ្ធរណ៍របស់ឈ្មោះ គិប ទង់ ចុះថ្ងៃទី ១៣.១២.៨៥ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ដែលបដិសេធចោលដោយទាត់ និង គតិច្បាប់ ។

២-ទទួលបណ្ដឹងឧទ្ធរណ៍ របស់ឈ្មោះ ឈួ ហាក់គាង ចុះថ្ងៃទី ១៨.០១.៨៦ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

៣-បដិសេធសាលក្រមលេខ ២៧០ ចុះថ្ងៃទី ២៤.១១.៨៥ របស់តុលាការខេត្តបាត់ដំបង ចោលជាអសារបង់ ។

៤-ប្រគល់ដីចំនាស់ដែលមានប្លង់បង្ហាញទីតាំងដីចំនាស់របស់ការិយាល័យសុរិយោដីខេត្តបាត់ដំបង មានជ្រុង BCDEE ស្ថិតនៅភូមិប្លាវែក ឃុំប្លាវែក ស្រុកស្វាយចេក ខេត្តបាត់ដំបង ទៅឲ្យឈ្មោះ ឈួ ហាក់គាង កាន់កាប់តទៅ និង បង្គាប់ឲ្យឈ្មោះ គិប ទង់ រុះរើផ្ទះចេញពីដីនេះ ។

៥-ប្រគល់ដីទំហំ ១៣ ព្យាម គុណ ១១ ព្យាម ស្ថិតនៅក្រុមទី ៣ ភូមិតាកុយ ឃុំកួលដូនទាវ ស្រុកស្វាយចេក ខេត្តបាត់ដំបង ទៅឲ្យឈ្មោះ គិប ទង់ កាន់កាប់ជាកម្មសិទ្ធិតទៅ ។

៦-បង្គាប់ឲ្យឈ្មោះ ឈួ ហាក់គាង ផ្ដល់ប្រាក់ចំនួន ២៥០.០០០៛ ទៅឲ្យឈ្មោះ គិប ទង់ សំរាប់សោហ៊ុយ ក្នុងការរុះរើ និង សាងសង់ឡើងវិញ ។

៧-ការយកប្រាក់ប្រដាប់ក្តី ជាន់សាលាឧទ្ធរណ៍ ចំនួន ១៣.០០០៛ គឺពន្ធចុះបញ្ជីក្តី និង ពន្ធថ្លឹង ២.៥៥០៛ រង្វាន់ក្រឡាបញ្ជីការចំពោះប្រាក់ ៤៥០៛ ចំណាយដើរកិច្ចប្រគល់ដីកាកោះ ៥.០០០៛ និង ចំណាយសើរើផ្ទាំងតុលាការ ៥.០០០៛ សរុប ១៣.០០០៛ ។ កាលបើពុំតការណ៍ប្តឹងឧទ្ធរណ៍ បង្គាប់អោយឈ្មោះ តិប ទង់ សងប្រាក់ប្រដាប់ក្តីចំនួន ១៣.០០០៛ ទៅអោយឈ្មោះ យួ ហាក់គាង វិញ ។

-បង្គាប់អោយឈ្មោះ យួ ហាក់គាង បង់ពន្ធមហាមាត្រ ១ភាគរយ នៃទឹកប្រាក់ ២៥០.០០០៛ និង ១ ភាគរយ នៃតម្លៃដី ដែលត្រូវប្រគល់ទៅអោយឈ្មោះ តិប ទង់ ។

៨-សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈ ចំពោះមុខគូក្តី បើកផ្លូវឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១៨៧ ចុះថ្ងៃទី ០៣.៦.៨៧ របស់ឈ្មោះតិបទង់ ធ្វើឡើងក្នុងកំណត់ច្បាប់ ។

បានឃើញសារណាចុះថ្ងៃទី ១៦.៥.៨៧ របស់ឈ្មោះ តិប ទង់ ។

បានឃើញសារណាតបចុះថ្ងៃទី ១៤.១២.៨៨ របស់ឈ្មោះ យួ ហាក់គាង ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ អមតុលាការកំពូលថា :

-សាលដីការដ្ឋប្បវេណីលេខ ២៦២ ចុះថ្ងៃទី ២០.៥.៨៧ របស់សាលាឧទ្ធរណ៍ បានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

ហេតុនេះសូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់តទៅ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ តិប ទង់ ជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះឆ្លើយថា :

-ខ្លួនរស់នៅលើដីនេះតាំងពីឆ្នាំ ១៩៧៩មក លុះដល់ឆ្នាំ ១៩៨៤ ប្រាប់ថាឈ្មោះ យួ ហាក់គាង រករឿងដេញខ្លួនអោយចេញពីដីនេះ ។ តុលាការខេត្តបានប្រគល់ដីនេះមកអោយខ្លួនគ្រប់គ្រង ដោយអោយខ្លួនបង់ប្រាក់ ៣០ម៉ឺនរៀល ទៅដើមចោទ តែខ្លួនគ្មានលុយ ។

បានស្តាប់ចម្លើយរបស់ឈ្មោះ យួ ហាក់គាង ជាចុងបណ្តឹងសាទុក្ខ នៅពេលជំនុំជំរះឆ្លើយថា :

-ដីនេះខ្លួនរស់នៅតាំងពីឆ្នាំ ១៩៧៩ លុះដល់ឆ្នាំ ១៩៨៤ ឈ្មោះតិប ទង់ មកសុំជ្រកនៅ ឯផលដំណាំ ខ្លួនជាអ្នកបេះផល លុះដល់ឆ្នាំ ១៩៨៣ ពេលខ្លួនទៅបេះដូងទាល់ ផងប្រាប់ថាឈ្មោះ តិប ទង់ មិនព្រមអោយបេះ ហើយគាត់ដេញកាប់ខ្លួន ។

ខ្លួនសុំសំណូមពរអោយឈ្មោះនេះ ចុះចេញពីដីរបស់ខ្លួន ព្រោះបើឈ្មោះនេះនៅបន្តទៀត នាំអោយមានអំពើហិង្សា ព្រោះឈ្មោះនេះបានជេរប្រមាថ និង ជេញកាប់ខ្លួន ។

មេធាវីរបស់ ចុងចម្លើយធ្វើសេចក្តីសន្និដ្ឋានថា :

-តាមអនុក្រឹត្យលេខ ២៥ អនក្រ កូនក្តីខ្លួនមានសិទ្ធិកាន់កាប់ ដីនេះជាកម្មសិទ្ធិ ព្រោះគាត់នៅមុនឆ្នាំ ១៩៨៥ ។ ឯដើមចោទអាចបេះផលដំណាំបានមកពីកូនក្តីខ្លួនយល់ថា ដីនេះជាដីរបស់ដើមចោទពីសង្គមចាស់ ដោយមានមនោសញ្ចេតនា កូនក្តីខ្លួនក៏អោយបេះទៅ ។ ចំណែកសាលាឧទ្ធរណ៍ សំរេចអោយដោះដូរដីនោះ គឺមិនត្រឹមត្រូវទេ ព្រោះកូនក្តីខ្លួនមិនយល់ព្រម ។

_ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ ចម្លើយដោះសារ របស់គូភាគី និង សេចក្តីសន្និដ្ឋាន របស់មេធាវី ចុងចម្លើយ

-ក្រោយពីបាន ពិភាក្សាត្រឹមត្រូវតាមច្បាប់រួចហើយ

តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១៣៧ ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ១៩៩៧ របស់លោក តឹប ទង់ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្តីពី ការបង្កើតនិង និងសកម្មភាពរបស់សាលាជំរះក្តី ។

-យល់ឃើញថា មុននឹងសំរេចរឿងនេះផងអង្គសេចក្តី តុលាការថ្នាក់ក្រោមបានធ្វើការអង្កេតស៊ើបសួរត្រឹមត្រូវតាមនីតិវិធីហើយ ។

-យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ដីទំនាស់នេះដើមចោទ បានចូលមកកាន់កាប់ គ្រប់គ្រងតាំងពីឆ្នាំ ១៩៧៩ មកព្រួកដំមែន ។ ចំណែកឯចុងចម្លើយ ទើបតែចូលមករស់នៅលើដីទំនាស់នេះក្នុងឆ្នាំ ១៩៨៥ ប៉ុណ្ណោះ ដោយគ្រាន់តែសង់ផ្ទះស្នាក់នៅតែលើមានទំហំ ៤ម គុណ ៥ម ឯផលដំណាំចាស់ គឺដើមចោទជាអ្នកទទួលផល និង បានដាំដំណាំថ្មីលើដីទំនាស់នេះ តាំងពីឆ្នាំ ១៩៧៩ រហូតដល់បច្ចុប្បន្ន ដោយពុំមានការតវ៉ាពីចុងចម្លើយទេ ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សំរេចអោយដើមចោទរកដីថ្មី និង ចេញសោហ៊ុយ [illegible] អោយចុងចម្លើយរុះរើផ្ទះទៅនៅលើដីថ្មីនោះ ជាការត្រឹម

ត្រូវ ហើយពីព្រោះថា ដីថ្មីនោះ ក៏មានលក្ខណៈសមស្រប អាចអោយចុងចម្លើយ រស់នៅបាននិងអាចជៀសវាងនូវទំនាស់ផ្សេងៗបានទៀតផងដែរ ។

-យល់ឃើញថា ខ្លឹមសារសាលា ចុះថ្ងៃទី ១៦.៥.៨៧ របស់លោកតឹបទង់ ដែលបានដាក់ជូនតុលាការកំពូល សាលាឧទ្ធរណ៍បានពិចារណារួចត្រឹមត្រូវ ហើយ ។

-យល់ឃើញថា ការដែលមេធាវីចុងចម្លើយលើកឡើងថា កូនក្តីរបស់លោកមានសិទ្ធិរស់នៅបន្ត លើដីទំនាស់ តាមអនុក្រឹត្យលេខ ២៥អនក្រ នោះ ជាការត្រឹមត្រូវហើយ ប៉ុន្តែដើម្បីជៀសវាងទំនាស់ តុលាការមានសមត្ថកិច្ចពិចារណា អំពីសិទ្ធិនេះ ម្យ៉ាងដោយដីនេះជាដីឃុំស្នឹង ដែលពុំអាចអោយជាកម្មសិទ្ធិបាន និង ម្យ៉ាងទៀត ការកាន់កាប់ របស់គូភាគី មានភាពប្រចបូកប្រចល់ ដែលគប្បីបំបែក គូភាគីអោយរស់នៅដាច់ ពីគ្នា ។

-យល់ឃើញថា សាលដីការរដ្ឋប្បវេណីលេខ ២៦២ ចុះថ្ងៃទី ២០.៥.៨៧ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវ តាមទំរង់ និងគតិច្បាប់ហើយ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី ចំពោះមុខ គូក្តី

១-ទទួលបណ្តឹងសាទុក្ខលេខ ១៨៧ ចុះថ្ងៃទី ០៣ ខែមិថុនា ឆ្នាំ ១៩៨៧ របស់លោក តឹប ទង់ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោល ដោយខុសនឹង គតិច្បាប់ ។

២-តម្កល់សាលដីការរដ្ឋប្បវេណីលេខ ២៦២ ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ ១៩៨៧ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងស្រុង ។

៣-រឹបអូសប្រាក់ប្រដាប់ក្តី ចំនួន ១៩.០០០ រៀល ដែលលោក តឹប ទង់ បានបង់រួចហើយគឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ៊ីង ចំនួន ៤.០០០ រៀល ប៉ុន្តែប្រាក់នេះ ត្រូវកាត់ចំនួន ៨០០ រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីការទីបប្រាក់ .

-ចំណាយលើកិច្ចប្រគល់ដីកាកោះ ចំនួន ១៥.០០០ រៀល សរុប ១៩.០០០ រៀល ។

បង្គាប់អោយអ្នកស្រី យូ ហាក់គាង បង់ពន្ធសមាមាត្រ តាមការកំណត់របស់សាលាឧទ្ធរណ៍ ។

៥-សាលដីកានេះ ប្រកាសនៅសវនាការជាសាធារណៈ នៅថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៩ ។